ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
'រ.ទ.ស.ភ'
លេខ ០៧២៣.២.៣

ភ្នំពេញ, ថ្ងៃទី២២ ខែមិនា ឆ្នាំ ២០១៧

**លិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា**
**ផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី**
**(ឆមាសទី២-ឆ្នាំ២០១៦)**

ខ្ញុំមានកិត្តិយសជម្រាបលោកប្រធានក្រុមហ៊ុន **៣៦៥ មូវីង ខូ អិលធីឌី** ថា ៖ ក្រោយពីការវាយតម្លៃលើឯកសារដេញថ្លៃពីគ្រប់ក្រុមហ៊ុន ដែលបានបើកជាសាធារណៈកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដើម្បីផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី (ឆមាសទី២-ឆ្នាំ២០១៦) រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានសម្រេចប្រគល់កិច្ចសន្យាជូនទៅក្រុមហ៊ុន **៣៦៥ មូវីង ខូ អិលធីឌី** ក្នុងតម្លៃកិច្ចសន្យាចំនួន ១៨៦,៥២១,០៨៤.៧៥រៀល (មួយរយប៉ែតសិបប្រាំមួយលានប្រាំរយម្ភៃមួយពាន់ប៉ែតសិបបួនរៀលនិងចិតសិបប្រាំសេន)។

អាស្រ័យហេតុនេះ សូមលោកប្រធានពិនិត្យ និងចុះហត្ថលេខាលើកិច្ចសន្យា ដែលបានជូនភ្ជាប់ រួចប្រគល់មករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយមានភ្ជាប់មកជាមួយនូវប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យា (Performance Security) ដោយអនុលោមទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា ក្នុងអំឡុងពេលមិនលើសពី១៥ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យានេះ។

សូមលោកប្រធានទទួលយកនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**បណ្ឌិត ជា ទិសុទ្ធ**

ចម្លងជូន៖
-ក្រុមហ៊ុន អិកវ៉េធើរ ថេកណូឡូជី
-ក្រុមហ៊ុន ហ្វ្រេនស៊ីប សឹបផ្លាយ
-ក្រុមហ៊ុន ឡុង គឹមប៊ិច ត្រេឌីង

អាសយដ្ឋានៈ លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទៈ ៨៥៥(២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh